# ករណីមិនធានា

**ករណីមិនធានាសម្រាប់ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍៖**

ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនធ្វើការទូទាត់សំណងឡើយ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងទទួលពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍តាមមូលហេតុដូចខាងក្រោម៖

1). ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬបង្កគ្រោះថ្នាក់ដោយខ្លួនឯង ទោះជាក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។

2). ការឆ្លងមេរោគហ៊ីវ (HIV) ជំងឺអេដស៍ (AIDS) ឬជំងឺដែលទាក់ទងនឹងជំងឺអេដស៍។

3). ចូលរួមក្នុងសកម្មភាពដូចជា សង្គ្រាម ការលុកលុយ បដិវត្តន៍ ការបះបោរ ចលាចលស៊ីវិល កុប្បកម្មកូដកម្ម ការកើនឡើងប្រជាប្រិយភាពប្រឆាំងនឹងរដ្ឋាភិបាល និងអំពើភេរវកម្ម។

4). ការប៉ុនប៉ងប្រព្រឹត្ត ឬប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬសកម្មភាពខុសច្បាប់ណាមួយ។

5). ការចូលរួមនៅក្នុងសកម្មភាពហោះហើរ ឬអាកាសចរណ៍នានា លើកលែងតែជាអ្នកដំណើរត្រូវបង់ថ្លៃធ្វើដំណើរនៃអាកាសចរណ៍ស៊ីវិល ដែលមានកាលវិភាគធ្វើដំណើរត្រឹមត្រូវ និងមានអាជ្ញាបណ្ណត្រឹមត្រូវ។

6). លទ្ធផលណាមួយនៃការធានារ៉ាប់រងបំពេញកាតព្វកិច្ចជាកងកម្លាំងប្រដាប់អាវុធ (យោធា នគរបាល ឆ្មាំប្រដាប់អាវុធ) ឬការបង្ក្រាបឧក្រិដ្ឋកម្ម ឬក្នុងសម័យសង្គ្រាម។

7). ពិការភាពណាមួយដែលបណ្តាលមកពីជំងឺ ការរងរបួស ឬការព្យាបាលរបស់អ្នកធានារ៉ាប់រង មុនពេលថ្ងៃចាប់ផ្តើមនៃបណ្ណសន្យារ៉ាប់រង។

8). ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

9). ជំងឺរាតត្បាតណាមួយ សំដៅលើការផ្ទុះឡើងនៃជំងឺធ្ងន់ធ្ងរ ដែលកំណត់ដោយក្រសួងសុខាភិបាល។

# ទំនាក់ទំនង

សម្រាប់ការសាកសួរព័ត៌មាន មតិយោបល់ ឬការទាមទារសំណង សូមទាក់ទងមកយើងខ្ញុំតាមរយៈ៖


011 255 200 (24/7)

061 431 111

support@rgi.com.kh

rgi.com.kh

Royal Group Insurance

ផ្ទះលេខ 14 ផ្លូវ 1003, ភូមិបាយ៉ាប, សង្កាត់ភ្នំពេញថ្មី, ខណ្ឌសែនសុខ, ភ្នំពេញ


Royal Group Insurance



# របាំងការពារ

## ROBANG KAPEA

ការការពារ ដែលស្ថិតនៅជាមួយ

**មនុស្សជាទីស្រឡាញ់**

របស់អ្នកជានិច្ច



# របាំងការពារ

## ROBANG KAPEA

ផលិតផលធានារ៉ាប់រង “**របាំងការពារ**” គឺជាផលិតផលធានារ៉ាប់រងមូលដ្ឋាន ជាក្រុមដែលបង្កើតឡើងដើម្បីការពារតណរន្តពីហានិភ័យផ្សេងៗ រួមទាំងការបាត់បង់អាយុជីវិត ពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍ ដែលបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ ឬជំងឺ។

នៅក្នុងព្រឹត្តិការណ៍បែបនេះ ក្រុមហ៊ុនធានារ៉ាប់រងនឹងទូទាត់ចំនួនទឹកប្រាក់ ដែលត្រូវបានធានារ៉ាប់រងសរុប ដោយផ្ទាល់ជាមួយម្ចាស់បំណុលដោយផ្អែកលើកាលវិភាគសងប្រាក់កម្ចី។

អត្ថប្រយោជន៍ធានារ៉ាប់រងដែលនៅសេសសល់ណាមួយ ប្រសិនបើអាចអនុវត្តបាន នឹងត្រូវបានផ្តល់ទៅឱ្យអ្នកទទួលផលបន្ទាប់បន្សំ។

# លក្ខណពិសេស នៃផលិតផល

| | | |
|---|---|---|
| អាយុចាប់ផ្តើមការធានា | : | ចាប់ពី 18ឆ្នាំ ដល់ 60ឆ្នាំ |
| សុពលភាពបណ្ណសន្យា/ រយៈពេលបង់បុព្វលាភ | : | 1 ឆ្នាំ |
| ចំនួនទឹកប្រាក់ធានារ៉ាប់រង | : | ចាប់ពី 50$ ឬ 20 ម៉ឺនរៀល ឬច្រើនជាងនេះ |
| ទីតាំងភូមិសាស្ត្រ នៃការធានា | : | ក្នុងព្រះរាជាណាចក្រកម្ពុជា និងទូទាំងសកលលោក |

# ការបង់បុព្វលាភ

| | | |
|---|---|---|
| ជម្រើស នៃការបង់ប្រាក់ | : | ប្រចាំឆ្នាំ ប្រចាំឆមាស ប្រចាំត្រីមាស ឬប្រចាំខែ |
| របៀបបង់ប្រាក់ | : | អាចបង់បានតាមរយៈសាច់ប្រាក់ ឬ ការផ្ទេរតាមធនាគារ។ |
| ការខកខានបង់ប្រាក់ | : | ប្រសិនបើការបង់ប្រាក់មិនបានបង់តាមកាលកំណត់ ហើយលើសពីរយៈពេលអនុគ្រោះ ៣០ ថ្ងៃ នោះបណ្ណសន្យានឹងត្រូវឮរ ហើយការការពារនឹងមិនមានសុពលភាពឡើយ។ |

# ការការពារ និងអត្ថប្រយោជន៍

**មរណភាពដោយសារមូលហេតុផ្សេងៗ៖** ក្នុងករណីមរណភាព ក្រុមហ៊ុននឹងទូទាត់សំណង ១០០% នៃទឹកប្រាក់ធានាជូនអ្នកទទួលផល ហើយបណ្ណសន្យានឹងត្រូវបញ្ចប់។

**ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (TPD) ដោយសារមូលហេតុផ្សេងៗ៖** ប្រសិនបើអ្នកធានារ៉ាប់រងពិការ ក្រុមហ៊ុននឹងទូទាត់សំណង ១០០% នៃទឹកប្រាក់ធានាជូនអ្នកទទួលផល។

*ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (TPD) សំដៅលើការបាត់បង់អវយវៈពីរ (២) ដែលបណ្តាលមកពីជំងឺ ឬគ្រោះថ្នាក់។*

**រាល់ ខ ចែង និងលក្ខខណ្ឌជាក់លាក់ទាំងអស់ត្រូវយោងទៅលើអត្ថន័យ ដែលមាននៅក្នុង ***វិញ្ញាបនបត្រធានារ៉ាប់រង*** របស់ក្រុមហ៊ុន។

# របៀបទាមទារសំណងធានារ៉ាប់រង

ងាយស្រួល និងរហ័សក្នុងការទាមទារសំណង

### ជំហានដំបូង

ទំនាក់ទំនងទៅកាន់ Hotline: **(855) 111 255 200** ដើម្បីជូនដំណឹងដល់ក្រុមហ៊ុនឱ្យបានបានឆាប់តាម ដែលអាចធ្វើទៅបាន។

បុគ្គលិកធានារ៉ាប់រង នឹងជួយអ្នកក្នុងរៀបចំឯកសារតម្រូវនានា ដើម្បីធ្វើការដាក់ស្នើទាមទារសំណងធានារ៉ាប់រង។

### ជំហានបន្ទាប់

ត្រូវបំពេញពាក្យទាមទារសំណង និងភ្ជាប់ជាមួយនឹងឯកសារតម្រូវ តាមការណែនាំ

**ស្កេនទីនេះ**

ដើម្បីដាក់ស្នើទាមទារសំណង

011 255 200 (24/7)

claims@rgi.com.kh

ផ្ទះលេខ១៤ ផ្លូវ១០០៣ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

# ករណីមិនធានា

### ករណីមិនធានាសម្រាប់មរណភាព៖

ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនធ្វើការទូទាត់សំណងឡើយ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាពតាមមូលហេតុដូចខាងក្រោម៖

1). ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬបង្កគ្រោះថ្នាក់ដោយខ្លួនឯង ទោះជាក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។

2). ការឆ្លងមេរោគហ៊ីវ (HIV) ជំងឺអេដស៍ (AIDS) ឬជំងឺដែលទាក់ទងនឹងជំងឺអេដស៍។

3). ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬការប៉ុនប៉ងប្រព្រឹត្តដោយអ្នកត្រូវបានធានា ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកទទួលផលបន្ទាប់បន្សំ ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ អ្នកទទួលផលដែលមិនពាក់ព័ន្ធ នៅតែមានសិទ្ធទទួលបានអត្ថប្រយោជន៍របស់ពួកគេ។

4). ចូលរួមក្នុងសកម្មភាពដូចជា សង្គ្រាម ការលុកលុយ បដិវត្តន៍ ការបះបោរ ចលាចលស៊ីវិល កុប្បកម្មកូដកម្ម ការកើនឡើងប្រជាប្រិយភាពប្រឆាំងនឹងរដ្ឋាភិបាល និងអំពើភេរវកម្ម។

5). លក្ខខណ្ឌដែលមានស្រាប់ដែលអ្នកត្រូវបានធានារ៉ាប់រងមិនបានបង្ហាញមកកាន់ក្រុមហ៊ុនមុនកាលបរិច្ឆេទជាធរមាននៃបណ្ណសន្យារ៉ាប់រង ហើយលក្ខខណ្ឌនេះរួមមានជំងឺរោគដែលធ្វើរោគវិនិច្ឆ័យឃើញ ឬពិការភាព ប៉ុន្តែមិនកំណត់ចំពោះជំងឺមហារីក ជំងឺទឹកនោមផ្អែម ជំងឺបេះដូង ជំងឺថ្លើម ជំងឺដាច់សរសៃឈាមខួរក្បាល ជំងឺសួត ជំងឺតម្រងនោម និងជំងឺរ៉ាំរ៉ៃ និងរបួសផ្សេងៗទៀត។

6). ជំងឺរាតត្បាតណាមួយ សំដៅលើការផ្ទុះឡើងនៃជំងឺធ្ងន់ធ្ងរដែលកំណត់ដោយក្រសួងសុខាភិបាល។

7). នៅក្នុងព្រឹត្តិការណ៍នៃសង្គ្រាម។